# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Nov-2018, 15:45
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**បណ្តឹងសាទុក្ខផ្ទាល់មាត់របស់លោក ខៀវ សំផន ប្រឆាំងនឹង**
**សាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨**

---

**ដាក់ដោយ៖**

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

**ដាក់ជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Agnieszka KLONOWIECKA-MILART

(ឬចៅក្រមជំនួស)

ចៅក្រម សោម សិរីវឌ្ឍ

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO

ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele Mwachande MUMBA

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្ដីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ "យោងតាមវិធាន ៩៨ នៃវិធានផ្ទៃក្នុង" អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគី និងសាធារណជនថា "អនុលោមតាមវិធាន ១០២(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងប្រកាសសេចក្តីសង្ខេបសំអាងហេតុ និងផ្នែកសម្រេចសេចក្តីនៃសាលក្រម នៅក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន"។ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់ផងដែរថា "អង្គជំនុំជម្រះនឹងជូនដំណឹងអំពីសំអាងហេតុពេញលេញនៃសាលក្រមនេះ នៅក្នុងពេលវេលាមួយសមស្រប"[1]។

២. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសវនាការជាសាធារណៈ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថាលោក ខៀវ សំផន ជាប់ពិរុទ្ធពីបទប្រល័យពូជសាសន៍(លើជនជាតិវៀតណាម) បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយបានផ្តន្ទាទោសលោក ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត[2]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងនឹងចេញសំអាងហេតុដែលសរសេរពេញលេញជាលាយលក្ខណ៍អក្សរ "ក្នុងពេលសមស្របខាងមុខ"[3]។

៣. តាមរយៈសារណានេះ មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") សូមប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ និងស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តាធ្វើមោឃភាពសាលក្រម ដោយមូលហេតុវិការៈទម្រង់ និងគ្មានសំអាងហេតុ[4]។

៤. ដោយសារមិនបានផ្តល់សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានរំលោភលើវិធានផ្ទៃក្នុង (ផ្នែកទី១) បានបង្កើតឲ្យមានស្ថានភាពច្របូកច្របល់ខាងនីតិវិធី និងអសច្ចភាពផ្លូវច្បាប់ (ផ្នែកទី ២) បានប្រព្រឹត្តកំហុសអង្គច្បាប់

---

[1] ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ **E462** ទំព័រ ២។

[2] ប្រតិចារឹកសវនាការ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ សេចក្តីព្រាង ចន្លោះម៉ោង [១១:២៨:០០] និង[១១:៣៨:១៧]។

[3] ប្រតិចារឹកសវនាការ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ សេចក្តីព្រាង បន្ទាប់ពីម៉ោង [០៩:៣៣:៣៦]។

[4] ផ្អែកលើបណ្តឹងសាទុក្ខនេះ សូមមើលខាងក្រោម ផ្នែកទី "២.១ ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនេះ" កថាខណ្ឌ ៩-៣៥។

ដែលធ្វើឲ្យសាលក្រមក្លាយជាមោឃៈ (ផ្នែកទី ៣) និងបានរំលោភលើសិទ្ធិក្នុងដំណើរការនីតិវិធី និងសិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន ដែលបង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរលើរូបគាត់ (ផ្នែកទី ៤)។

## ១. ការរំលោភលើវិធានផ្ទៃក្នុង

៥. អង្គជំនុំជម្រះសាលាដំបូងមិនត្រូវបានអនុញ្ញាតឲ្យប្រកាសសេចក្តីសង្ខេបសំអាងហេតុ និងផ្នែកសម្រេចសេចក្តីនៃសាលក្រម ជាមុនសិន រួចទើបផ្តល់សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរ តាមក្រោយ បន្ទាប់ពីថ្ងៃប្រកាសសាលក្រម នោះឡើយ។

៦. វិធាន ១០១ និងវិធាន ១០២ នៃវិធានផ្ទៃក្នុង ចែងដោយគ្មានស្រពេចស្រពិល៖

"**វិធាន ១០១៖ ទម្រង់ការនៃសាលក្រម**

(វិសោធនកម្ម ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០)

១. **សាលក្រមត្រូវចែកជាពីរផ្នែក៖**

ក- **ផ្នែកសំអាងហេតុ** គឺជាការយល់ឃើញអំពីមូលហេតុខាងអង្គហេតុ និងអង្គច្បាប់ ដែលនាំឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេច

ខ- **ផ្នែកសម្រេចសេចក្តី**របស់អង្គជំនុំជម្រះ

២. ប្រសិនបើមិនមានសំឡេងជាឯកច្ឆន្ទទេ ចៅក្រមអាចសរសេរយោបល់ដោយឡែកមួយផ្សេង ឬយោបល់ជំទាស់ នៅក្នុងករណីនេះ ហើយត្រូវភ្ជាប់ទៅនឹងសាលក្រម។

៣. អង្គជំនុំជម្រះត្រូវពិនិត្យលើរាល់បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងពិចារណាលើលទ្ធផលនៃកិច្ចពិភាក្សាដេញដោលដែលបានលើកឡើងក្នុងពេលជំនុំជម្រះ។

៤. ផ្នែកសំអាងហេតុនៅក្នុងសាលក្រម ត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលបានធ្វើឡើងដោយភាគីទាំងអស់។

៥. ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបញ្ជាក់ពីបទល្មើសនីមួយៗ ដែល

ប្រព្រឹត្តដោយជនជាប់ចោទ ច្បាប់ជាធរមាន ការផ្តន្ទាទោស និងសំណង។

៦. **សាលក្រមត្រូវតែចុះហត្ថលេខាដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង និងក្រឡាបញ្ជី។** ចៅក្រម ដែលមានយោបល់ជំទាស់ ត្រូវចុះហត្ថលេខាតែនៅលើឯកសារផ្តល់យោបល់ដោយឡែក ឬយោបល់ជំទាស់របស់ខ្លួនតែប៉ុណ្ណោះ។ សាលក្រមត្រូវមានចុះសេចក្តីដូចខាងក្រោម៖

ក- កាលបរិច្ឆេទនៃសវនាការ

ខ- កាលបរិច្ឆេទនៃការប្រកាសសាលក្រម

គ- ឈ្មោះរបស់ចៅក្រមដែលជំនុំជម្រះ

ឃ- ឈ្មោះរបស់សហព្រះរាជអាជ្ញា

ង- ឈ្មោះរបស់ក្រឡាបញ្ជី

ច- ឈ្មោះពេញ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត និងមុខរបររបស់ជនជាប់ចោទ

ឆ- ឈ្មោះពេញរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអាសយដ្ឋានបច្ចុប្បន្ន ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត និងមុខរបរ នៅពេលដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំ

ជ- ឈ្មោះពេញរបស់មេធាវី និង

ឈ- សិទ្ធិប្តឹងសាទុក្ខរបស់ភាគី និងលក្ខខណ្ឌ និងពេលវេលាកំណត់សម្រាប់ប្តឹងសាទុក្ខ។

៧. **សាលក្រមដើម** ដែលមានទម្រង់ដូចខាងលើ **ត្រូវចុះហត្ថលេខា** **<u>យ៉ាងយូរបំផុតនៅថ្ងៃចេញសាលក្រម</u>**" (យើងខ្ញុំជាអ្នកដាក់អក្សរដិត និងគូសបន្ទាត់ពីក្រោម)។

"**វិធាន ១០២÷ ការប្រកាសសាលក្រមនៅសវនាការសាធារណៈ**:"

(វិសោធនកម្ម ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨)

១. គ្រប់សាលក្រមទាំងអស់ត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ។ ផ្នែកសង្ខេបនៃ

សំអាងហេតុ និងផ្នែកសម្រេចសេចក្តីត្រូវតែអានខ្លាំងៗដោយប្រធានអង្គជំនុំជម្រះសាលាដំបូង ឬសមាជិកនៃអង្គជំនុំជម្រះណាម្នាក់។ ចៅក្រមដែលមានយោបល់ផ្ទុយ អាចអានដោយផ្ទាល់មាត់នូវសេចក្តីសង្ខេបគំនិតផ្ទុយរបស់ខ្លួន។ **ក្រឡាបញ្ជីត្រូវផ្តល់សាលក្រមចម្លងមួយច្បាប់ទៅឱ្យភាគីទាំងឡាយ** និងត្រូវធានាថាសាលក្រមត្រូវបានផ្សព្វផ្សាយដោយការិយាល័យរដ្ឋបាលតាមមធ្យោបាយសមស្រប។

២. **បើសិនជាជនជាប់ចោទអវត្តមាននៅពេលប្រកាសសាលក្រម** ជនជាប់ចោទនឹងត្រូវបានជូនដំណឹងតាមរយៈមេធាវីរបស់ខ្លួន ឬតាមរយៈមេធាវីដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង។ **កាលកំណត់បណ្តឹងសាទុក្ខគិតចាប់ពីថ្ងៃជូនដំណឹង**។ (យើងខ្ញុំជាអ្នកដាក់អក្សរដិត)។

៧. ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចផ្តល់សាលក្រមជាលាយលក្ខណ៍អក្សរនៅថ្ងៃប្រកាសតែម្តង។ សាលក្រមនេះត្រូវចុះហត្ថលេខាដោយចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងក្រឡាបញ្ជី "យ៉ាងយូរបំផុត" នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយសំណៅចម្លងមួយច្បាប់ត្រូវផ្តល់ជូនភាគី និងត្រូវបោះពុម្ពផ្សាយ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ អង្គជំនុំជម្រះសាលាដំបូងត្រូវសរសេរ និងចុះហត្ថលេខាសាលក្រមជាមុនសិន មុននឹងប្រកាស គឺមិនត្រូវធ្វើបញ្ច្រាសឡើយ។

## ២. <u>ភាពច្របូកច្របល់ខាងនីតិវិធី និងអសច្ចភាពផ្លូវច្បាប់</u>

៨. ការចេញសាលក្រម ដោយមិនគោរពតាមទម្រង់ការ ដូចបានចែងនៅក្នុងវិធានផ្ទៃក្នុង បង្កឱ្យមានភាពច្របូកច្របល់ខាងនីតិវិធី និងអសច្ចភាពផ្លូវច្បាប់ មិនត្រឹមតែលើភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនេះទេ (ផ្នែកទី ២.១) គឺថែមទាំងលើសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរដែលនឹងចេញនាពេលខាងមុខ ទៀតផង (ផ្នែកទី ២.២)។

### ២.១. <u>ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនេះ</u>

៩. មេធាវីការពារក្តីមិនអាចដឹងប្រាកដទាំងស្រុងអំពីផលវិបាកខាងនីតិវិធី នៃសេចក្តីសម្រេច ដែលអង្គជំនុំជម្រះសាលាដំបូងបានចេញផ្ទាល់មាត់ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នោះទេ។ ដូច្នេះ មេធាវីការពារក្តីស្នើឡើងនូវមូលដ្ឋានមួយចំនួន ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនេះ៖ វិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុង (ផ្នែកទី ២.១.ក) វិធាន ១០៥(២) និងវិធាន ១០៤(៤)(ក)

(ផ្នែកទី ២.១.ខ) ឬយុត្តាធិការជាប់មកជាមួយស្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល (ផ្នែកទី ២.១.គ)។

## ២.១.ក. វិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុង

១០. សេចក្តីសម្រេច នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងចាត់ទុកដូចជាសាលក្រម ក្នុងសំណុំរឿង ០០២/០២។ នៅក្នុងដីកា ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ "កំណត់កាលបរិច្ឆេទប្រកាសសាលក្រម" នៅថ្ងៃទី១៦ ខែវិច្ឆិកា អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនូវវិធាន ៩៨ និងវិធាន ១០២(១) នៃវិធានផ្ទៃក្នុង (មានចំណងជើងរៀងគ្នាថា "សាលក្រម" និង "ការប្រកាសសាលក្រមនៅសវនាការសាធារណៈ:")។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថានឹងផ្តល់ "សេចក្តីសង្ខេបសំអាងហេតុ និងផ្នែកសម្រេចសេចក្តីនៃសាលក្រម"។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើដូច្នេះ នៅថ្ងៃទី១៦ ខែវិច្ឆិកា ដោយបានប្រកាសពិរុទ្ធភាព និងទោសរបស់ជនជាប់ចោទ[5]។

១១. បើសិនជាអង្គជំនុំជម្រះសាលាដំបូងបានចេញផ្នែកសម្រេចសេចក្តីនៃសាលក្រម ហើយផ្នែកសម្រេចសេចក្តីនេះ គឺជា "សេចក្តីសម្រេចផ្ទាល់តែម្តង" ដូចបានរម្លឹកដោយវិធាន ១០១(១)(ខ) នៃវិធានផ្ទៃក្នុង[6] នោះមានន័យថា អង្គជំនុំជម្រះបានចេញសាលក្រម ក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នោះតែម្តង។

១២. ក្នុងលក្ខខណ្ឌនេះ បណ្តឹងសាទុក្ខនេះគួរត្រូវទទួលយក ផ្អែកលើវិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុង ដែលផ្តល់លទ្ធភាពឲ្យជនជាប់ចោទធ្វើ "បណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង"។

១៣. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ បន្ទាប់ពីបានធ្វើការប្រកាសសេចក្តីសម្រេចក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានធ្វើការ "បំភ្លឺ" ទាក់ទងនឹងចំណុចចាប់ផ្តើមនៃកាលកំណត់សម្រាប់ធ្វើបណ្តឹងសាទុក្ខ៖

> "អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា អនុលោមតាមវិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក រយៈពេល

[5] សូមមើលខាងលើ កថាខណ្ឌ ១ និងកថាខណ្ឌ ២។

[6] សូមមើលខាងលើ កថាខណ្ឌ ៦។

ពេលកំណត់សម្រាប់ការដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ។ ប្រសិនបើមាន នឹងត្រូវចាប់ផ្តើមរាប់មួយថ្ងៃបន្ទាប់នៃថ្ងៃប្រក្រតីទិន ក្រោយពីការបញ្ជូននូវការជូនដំណឹងពីសាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញជាភាសាខ្មែរ និងភាសាផ្លូវការណាមួយផ្សេងទៀតរបស់ អ.វ.ត.ក ដែលភាគីនីមួយៗបានជ្រើសរើស ដោយអនុលោមទៅតាមមាត្រា ២.២ នៃសេចក្តីណែនាំអនុវត្ត។"[7]

១៤. "ការបញ្ជាក់"នេះ គឺខុសខ្លាំងណាស់ ប្រសិនបើយើងអានអោយច្បាស់លាស់បទបញ្ញត្តិនៃវិធានផ្ទៃក្នុង (ក) និង សេចក្តីណែនាំអនុវត្ត (ខ)។

ក- <u>ចំណុចចាប់ផ្តើមពេលវេលាកំណត់ដោយយោងតាមវិធានផ្ទៃក្នុង</u>

១៥. កាលកំណត់ធ្វើបណ្តឹងសាទុក្ខគិតចាប់ពីថ្ងៃប្រកាសសាលក្រម។ ជាក់ស្តែង យោងតាមវិធាន ១០៧ (៤) នៃវិធានផ្ទៃក្នុង "សេចក្តីសុំប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដូចមានកំណត់នៅក្នុងវិធាន ១០៥(៣)" ត្រូវធ្វើក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬថ្ងៃជូនដំណឹងពីសាលក្រមនោះ តាមករណីសមស្រប"។ អនុលោមតាមវិធាន ១០២(២) កាលកំណត់បណ្តឹងសាទុក្ខ ចាប់គិតពីថ្ងៃជូនដំណឹងអំពីសាលក្រម "បើសិនជាជនជាប់ចោទអវត្តមាននៅពេលប្រកាសសាលក្រម"[8]។ និយាយម្យ៉ាងទៀត បើសិនជាជនជាប់ចោទមានវត្តមាន នៅពេលប្រកាសសាលក្រម កាលកំណត់សម្រាប់បណ្តឹងសាទុក្ខគិតចាប់ពីថ្ងៃប្រកាសសាលក្រម។

១៦. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាថែងកាន់តែច្បាស់លាស់ថែមទៀត អំពីពេលចាប់ផ្តើមគិតកាលកំណត់បណ្តឹងសាទុក្ខ។ យោងតាមមាត្រា ៣៨១ រយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា "ផ្តើមគិតពីពេលប្រកាសសាលក្រម"។ យោងតាមមាត្រា ៣៨២ ការប្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ "ត្រូវតែធ្វើក្នុងរយៈពេលមួយខែ។ កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម។ កាលណាសាលក្រមនោះចាត់ទុកថាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ"។ អនុលោមតាមក្រមនេះដដែល "ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ" នោះ

[7] ប្រតិចារឹកសវនាការ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ សេចក្តីព្រាង ម៉ោង [១១:៣៨:១៧]។

[8] សូមមើលខាងលើ កថាខណ្ឌ ៦។

សាលក្រមជាសាលក្រមចំពោះមុខជនជាប់ចោទ" (មាត្រា ៣៦០ វាក្យខណ្ឌ ១)។ ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែ សាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះ សាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ" (មាត្រា ៣៦១ វាក្យខណ្ឌ ១)។

១៧. ក្នុងរឿងក្តីនេះ លោក ខៀវ សំផន មានវត្តមានពេលប្រកាសសាលក្រម នៅថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយបណ្តឹងសាទុក្ខនេះបានដាក់នៅថ្ងៃច័ន្ទបន្ទាប់ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ គឺ ៣ (បី) ថ្ងៃក្រោយមក។

**ខ- ចំណុចចាប់ផ្តើមពេលវេលាកំណត់ដោយយោងតាមសេចក្តីណែនាំអនុវត្ត**

១៨. មាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងមានដូចតទៅ ៖

«លើកលែងតែមានការណែនាំផ្ទុយពីនេះរបស់សហចៅក្រមស៊ើបអង្កេត ឬពីអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក ពេលវេលាកំណត់ត្រូវចាប់ផ្តើមគិតពីថ្ងៃបន្ទាប់នៃថ្ងៃជូនដំណឹងអំពីឯកសារជាភាសាខ្មែរ និងភាសាផ្លូវការមួយទៀតរបស់ អ.វ.ត.ក ។ ក្នុងករណីពិសេស សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចសម្រេចថា ពេលវេលាកំណត់ត្រូវចាប់ផ្តើមគិត ពីថ្ងៃបន្ទាប់នៃថ្ងៃដាក់ឯកសារជាបីភាសាផ្លូវការ »។

១៩. ដូច្នេះ ផ្ទុយពីការអះអាងរបស់អង្គជំនុំជម្រះសាលាដំបូង ពេលវេលាកំណត់ត្រូវចាប់ផ្តើមគិតពីថ្ងៃបន្ទាប់នៃថ្ងៃជូនដំណឹងអំពីឯកសារជាភាសាខ្មែរ និងភាសាផ្លូវការមួយទៀតរបស់ អ.វ.ត.ក ទោះបីជាមិនមែនជាភាសាដែលត្រូវបានជ្រើសរើសដោយភាគី ស្របតាមមាត្រា ២.២ នៃសេចក្តីណែនាំអនុវត្តក៏ដោយ។ គេអាចនិយាយម៉្យាងទៀតថា បើឧបមាថា សាលក្រមត្រូវបានដាក់ចេញជាភាសាខ្មែរ និងភាសាអង់គ្លេស នៅថ្ងៃប្រកាសសាលក្រម ដូច្នេះពេលវេលាកំណត់សម្រាប់ធ្វើបណ្តឹងសាទុក្ខត្រូវចាប់ផ្តើមរាប់ចាប់ពីថ្ងៃបន្ទាប់ទៅ ហើយមេធាវីការពារក្តីដែលជ្រើសរើសការប្រើប្រាស់ភាសាបារាំង ជាអ្នកស្នើសុំដល់អង្គជំនុំជម្រះតុលាការកំពូលឲ្យលើកពេលវេលាកំណត់សម្រាប់ដាក់បណ្តឹងសាទុក្ខ ចាប់ពីពេលជូនដំណឹងសាលក្រមជាបីភាសាផ្លូវការនៃអ.វ.ត.ក។

២០. ក្នុងករណីនេះ បញ្ហាខាងលើមិនអាចចោទឡើងឡើយ ពីព្រោះថា ថ្ងៃទី ១៦ ខែវិច្ឆិកាឆ្នាំ ២០១៨ គឺជាពេលចាប់ផ្តើមពេលវេលាកំណត់សម្រាប់ធ្វើបណ្តឹងសាទុក្ខ តែអង្គជំនុំជម្រះមិនទាន់បានចេញសាលក្រមជាលាយលក្ខណ៍អក្សរនៅឡើយទេ។

## ២.១.២. វិធាន ១០៥(២) និងវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង

២១. អវត្តមានសាលក្រមជាលាយលក្ខណ៍អក្សរ ពុំអាចឲ្យគេអនុវត្តបានយ៉ាងម៉ឺងម៉ាត់នូវនីតិវិធីប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង បានឡើយ។

២២. យោងតាមវិធាន ១០៨(១) នៃវិធានផ្ទៃក្នុង ក្នុងករណីមានបណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង "ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងត្រូវបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ដោយភ្ជាប់ជាមួយនូវឯកសារថតចម្លងនៃសាលក្រម [...] ដែលមានសេចក្តីបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវ"។ ចំណុចនេះមិនអាចធ្វើបានឡើយក្នុងរឿងក្តីនេះ។

២៣. ហេតុដូច្នេះ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានចេញផ្នែកសម្រេចសេចក្តីនៃសាលក្រម ពោលគឺសាលក្រមផ្ទាល់តែម្តង ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលអាចយល់ឃើញថា នេះមិនមែនជាសាលក្រមពិតប្រាកដ ស្របតាមវិធានដែលគ្រប់គ្រងការធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅចំពោះមុខ អ.វ.ត.ក នោះទេ។

២៤. ដូច្នេះ ក្នុងស្ថានភាពបែបនេះ យើងគួរចាត់ទុកសេចក្តីសម្រេចចេញថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ថាយ៉ាងហោចណាស់ ជាសេចក្តីសម្រេចមាន "អានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" និងបើកផ្លូវប្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៥(២) និងវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង។

២៥. អនុលោមតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល សិទ្ធិប្តឹងសាទុក្ខ ដូចមានចែងនៅក្នុងវិធាន ១០៤(៤)(ក) មានគោលបំណង "ធានាថាបណ្តឹងសាទុក្ខភ្លាមៗអាចធ្វើទៅបាន នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ ដោយពុំបានចេញសាលក្រម ដែលធ្វើឲ្យគ្មានឱកាសក្នុងការប្តឹងសាទុក្ខលើសាលក្រមនោះ"[9]។

២៦. ក្នុងរឿងក្តីនេះ អង្គជំនុំជម្រះតុលាការកំពូលអាចពិចារណាថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងពិរុទ្ធភាព និងការផ្តន្ទាទោសជនជាប់ចោទ ក្នុងសំណុំរឿង ០០២/០២ បាន

---

[9] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ **E301/9/1/1/3** កថាខណ្ឌ ១៧។

បញ្ចប់កិច្ចដំណើរការនីតិវិធី ដោយពុំបានឈានដល់ការចេញសាលក្រមមួយដែលអាចបើកផ្លូវប្តឹងសាទុក្ខ។ ជាក់ស្តែង ដូចបានលើកឡើងខាងក្រោម សិទ្ធិធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម គឺជាសិទ្ធិសុំឲ្យពិនិត្យលើអង្គសេចក្តីនៃការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោស។ ក៏ប៉ុន្តែ លោក ខៀវ សំផន ពុំមានលទ្ធភាពអនុវត្តសិទ្ធិនេះបានទេ[10]។

២៧. លើសពីនេះទៀត បណ្តឹងសាទុក្ខទាក់ទងនឹងទម្រង់ការនៃសាលក្រមនេះ ត្រូវបានដាក់ក្នុងរយៈពេលកំណត់សម្រាប់បណ្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ពោលគឺក្នុង "រយៈពេល ៣០ (សាមសិប) ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេច ឬពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនោះ" ដូចមានចែងនៅក្នុងវិធាន ១០៧(១)។

## ២.១.គ. យុត្តាធិការជាប់មកជាមួយស្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល

២៨. ក្នុងករណីបណ្តឹងសាទុក្ខនេះត្រូវបានវាយតម្លៃថាមិនអាចទទួលយកបាន ដោយផ្អែកលើបទប្បញ្ញត្តិនានាដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលគប្បីអនុវត្តយុត្តាធិការជាប់មកជាមួយស្រេចរបស់ខ្លួន។

២៩. ដូចអង្គជំនុំជម្រះតុលាការកំពូលបានរម្លឹកអំពីករណីនេះ ដោយយោងលើសេចក្តីសម្រេចមួយរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ថា "[តុលាការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការដែលមានស្តង់ដារអន្តរជាតិ] បានយល់ឃើញថា នៅក្នុងករណីដែលបទប្បញ្ញត្តិលក្ខន្តិកៈរបស់ខ្លួនមិនចែងពីអំណាចរបស់ខ្លួនឲ្យបានច្បាស់លាស់ ឬឲ្យជាប់ពាក់ព័ន្ធជាសារវន្តក្នុងការសម្រេចលើបញ្ហាណាមួយនោះ តុលាការទាំងនោះមានយុត្តាធិការជាប់រួចជាស្រេចមួយ ដើម្បីសម្រេចលើបញ្ហាចៃដន្យដែលកើតចេញពីលទ្ធផលផ្ទាល់នៃកិច្ចដំណើរការនីតិវិធី ដែលតុលាការទាំងនោះបានទទួល ដោយផ្តល់សំអាងហេតុថា បញ្ហានោះស្ថិតនៅក្រោមយុត្តាធិការបឋមរបស់ខ្លួន"[11]។

---

[10] សូមមើលខាងក្រោម ផ្នែកទី "៣. កំហុសអង្គច្បាប់ដែលនាំឲ្យសាលក្រមក្លាយជាមោឃៈ" កថាខណ្ឌ ៥៨-៦៣។

[11] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E284/2/1/2** កថាខណ្ឌ ១២ យោងទៅ៖ រឿងក្តី *Sayed* លេខ CH/1C/2010/02 តុលាការពិសេសសម្រាប់ប្រទេសលីបង់, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ចៅក្រមស៊ើបអង្កេត លើយុត្តាធិការ និងសិទ្ធិប្តឹងតវ៉ា ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៤៥ កថាខណ្ឌ ៤៦ និងកថាខណ្ឌ ៤៨។

៣០. អនុលោមតាមសេចក្ដីសម្រេចនេះរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ យុត្តាធិការជាប់មកជាមួយស្រេច "ត្រូវបានចាត់ទុកជាយុត្តាធិការចាំបាច់ដោយគោលការណ៍គ្រប់គ្រងតុលាការឲ្យបានល្អ និងប្រកបដោយយុត្តិធម៌ ជាពិសេស ការគោរពឲ្យបានពេញលេញនូវសិទ្ធិជាមូលដ្ឋាន"[12]។ "យោងតាមការអនុវត្តរបស់តុលាការអន្តរជាតិ វិធានដែលផ្ដល់យុត្តាធិការជាប់មកជាមួយស្រេចដល់តុលាការអន្តរជាតិ មានគោលដៅជាទូទៅ ដើម្បីបំពេញចន្លោះប្រហោងដែលអាចកើតមានក្នុងការរៀបចំបទបញ្ញាតតិយុត្តិនៃកិច្ចដំណើរការនីតិវិធី។ ជាពិសេស វិធាននេះមានគោលដៅជាអាទិ៍៖ (១) ធានាការគ្រប់គ្រងតុលាការឲ្យបានល្អ (២) ត្រួតពិនិត្យកិច្ចដំណើរការនីតិវិធី និងការដឹកនាំការជំនុំជម្រះក្ដីឲ្យបានល្អ [...]"[13]។

៣១. វិធីសាស្ត្រនេះធ្លាប់ត្រូវបានអនុវត្តរួចមកហើយ នៅក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក និងជាពិសេសក្នុងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ឧទាហរណ៍ ពាក់ព័ន្ធនឹងការបង្អង់ការអនុវត្តសេចក្ដីសម្រេចមួយចំនួន ទម្រាំមានសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការស្នើសុំឲ្យពិនិត្យឡើងវិញ ឬកំហុសនីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត[14]។

៣២. ក្នុងរឿងក្ដីនេះ ដោយសារពុំមានបទប្បញ្ញត្តិជាក់លាក់គ្រប់គ្រងស្ថានភាពដែលអង្គជំនុំជម្រះសាលាដំបូងបានបង្កើតឡើង ហើយដែលករណីបែបនេះមិនត្រឹមតែពុំមានចែងក្នុងវិធានផ្ទៃក្នុងប៉ុណ្ណោះទេ ថែមទាំងផ្ទុយនឹងវិធានផ្ទៃក្នុងទៀតផង ហើយក្នុងឋានៈជាតុលាការសម្រេចលើបណ្ដឹងសាទុក្ខនៅដំណាក់កាលជំនុំជម្រះ អង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើអន្តរាគមន៍ដើម្បីជាប្រយោជន៍យុត្តិធម៌។

៣៣. អន្តរាគមន៍ភ្លាមៗរបស់អង្គជំនុំជម្រះតុលាការកំពូលពិតជាចាំបាច់ ពីព្រោះដូចបានលើកឡើងខាងក្រោម អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ ដែលនាំឲ្យសេចក្ដីសម្រេចរបស់ខ្លួនក្លាយជាមោឃៈ និងបានរំលោភសិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន។

---

[12] រឿងក្ដី *Sayed* លេខ CH/1C/2010/02 តុលាការពិសេសសម្រាប់ប្រទេសលីបង់ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ចៅក្រមស៊ើបអង្កេត លើយុត្តាធិការ និងសិទ្ធិប្ដឹងតវ៉ា ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៤៥។

[13] រឿងក្ដី *Sayed* លេខ CH/1C/2010/02 តុលាការពិសេសសម្រាប់ប្រទេសលីបង់ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ចៅក្រមស៊ើបអង្កេត លើយុត្តាធិការ និងសិទ្ធិប្ដឹងតវ៉ា ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៤៨។

[14] ដីកាសម្រេចព្យួរការអនុវត្ត "ដីកាសម្រេចស្ដីពីសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ ឯកសារ **D14/1/2** និងការយោងទាំងអស់នៅក្នុងកំណត់សម្គាល់ជើងទំព័រ ១១ និង ១២។

## ការបញ្ជាក់ទាក់ទងនឹងទម្រង់ការនៃបណ្តឹងសាទុក្ខនេះ

៣៤. ការបង្ខំចិត្តរបស់មេធាវីការពារក្តីក្នុងការធ្វើការបែបស្មានៗ ដើម្បីអនុវត្តនូវសិទ្ធិជាមូលដ្ឋានក្នុងការធ្វើបណ្តឹងសាទុក្ខនេះ គឺជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ដោយសារភាពមិនច្បាស់លាស់ជុំវិញមូលដ្ឋាននៃភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនេះ និងយោងតាមភាពបន្ទាន់នៃបញ្ហាដែលកើតមានឡើង មេធាវីការពារក្តីសូមដាក់បណ្តឹងសាទុក្ខនេះ ក្រោមទម្រង់ជាសារណា ស្របតាមលទ្ធភាពពីរ ក្នុងចំណោមលទ្ធភាពទាំងបីដែលបានគិតទុក (បណ្តឹងសាទុក្ខភ្លាមៗ និងយុត្តាធិការជាប់មកជាមួយស្រេច)។

៣៥. ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសម្រេចថាបណ្តឹងសាទុក្ខនេះអាចទទួលយកបាន ផ្អែកតាមវិធាន ១០៥(១)(ខ) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលត្រូវចាត់ទុកសារណានេះជាករណីលើកលែងថាជាសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខផង និងជាសារណាបណ្តឹងសាទុក្ខផង[15]។ ជាការពិត ភាពខុសគ្នារវាងឯកសារទាំងពីរនេះ ដូចមានចែងក្នុងវិធាននេះ ត្រូវបានបង្កើតឡើង ដើម្បីអនុញ្ញាតឲ្យម្ចាស់បណ្តឹងសាទុក្ខអាចលើកឡើងពីទឡ្ហីករណ៍របស់ខ្លួន ទាំងអង្គច្បាប់ និងអង្គហេតុ។ ក្នុងរឿងក្តីនេះ ដោយសារសាលក្រមពុំមានសំអាងហេតុពេញលេញ មានតែបញ្ហាគោរពកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ ដែលត្រូវលើកយកមកពិភាក្សា។

## ២.២. សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរដែលនឹងចេញនាពេលខាងមុខ

៣៦. ភាពច្របូកច្របល់ខាងនីតិវិធី និងអសច្ចភាពផ្លូវច្បាប់ ដែលអង្គជំនុំជម្រះសាលាដំបូងបានបង្កឡើងលាតសន្ធឹងដល់សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរ ដែលត្រូវបានប្រកាសថានឹងត្រូវចេញ "នៅក្នុងពេលវេលាមួយសមស្រប" ហើយចាប់ពីពេលនេះទៅ សំអាងហេតុនេះត្រូវចាត់ទុកថាគ្មានសុពលភាព (ក)។ ការអនុវត្តការបែងចែកដំណើរការធ្វើសេចក្តីសម្រេចជាពីរដំណាក់កាលនៅ អ.វ.ត.ក (ខ) ត្រូវបានហាមឃាត់ជាផ្លូវការ ក្នុងករណីជាសាលក្រម (គ)។

### ២.២.ក. ការចប់ភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង និងអសុពលភាពនៃសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរដែលនឹងចេញនាពេលខាងមុខ

---

[15] អនុលោមតាមវិធាន ១០៥(៣)៖ "ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ" "បន្ទាប់មក ម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់សារណាបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ"។

៣៧. ប្រសិនបើនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញផ្នែកសម្រេចសេចក្តីនៃសាលក្រម ពោលគឺសាលក្រមផ្ទាល់តែម្តង អង្គជំនុំជម្រះត្រូវចប់ភារកិច្ចពីសំណុំរឿង ចាប់តាំងពីថ្ងៃនោះមក។ អង្គជំនុំជម្រះបានសម្រេចលើវិវាទចម្បងដែលខ្លួនត្រូវបានស្នើសុំឲ្យពិនិត្យ ហើយហេតុដូច្នេះ អង្គជំនុំជម្រះបានប្រើអំណាចយុត្តាធិការរបស់ខ្លួនអស់ហើយ។ អានុភាពនៃការបញ្ចប់ភារកិច្ចរបស់ចៅក្រមដែលភ្ជាប់នឹងសាលក្រម ត្រូវបានស្តែងឡើងដោយបុរាណភាសិតឡាតាំង *lata sententia, judex desinit esse judex*៖ ក្រោយចេញសាលក្រមរួច ចៅក្រមលែងជាចៅក្រមទៀតហើយ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងលែងមានយុត្តាធិការចេញសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរទៀតហើយ ហើយការបន្តសរសេរសំអាងហេតុ គឺការរំលោភអំណាច។

៣៨. អង្គជំនុំជម្រះសាលាដំបូងប្រហែលជាយល់ខុសថា ខ្លួនអាចធ្វើដូច្នេះបាន ដោយសារការអនុវត្តការបែងចែកដំណើរការធ្វើសេចក្តីសម្រេចជាពីរដំណាក់កាល ដែលកើតមានញឹកញាប់នៅ អ.វ.ត.ក។

## ២.២.១. ការអនុវត្តការបែងចែកដំណើរការធ្វើសេចក្តីសម្រេចជាពីរដំណាក់កាលនៅ អ.វ.ត.ក

៣៩. អង្គជំនុំជម្រះនីមួយៗរបស់ អ.វ.ត.ក សុទ្ធតែធ្លាប់បានចេញផ្នែកសម្រេចសេចក្តីនៃសេចក្តីសម្រេចមួយចំនួនរបស់ខ្លួន ជាមុន (ដោយមាន ឬគ្មានសេចក្តីសង្ខេបសំអាងហេតុ) រួចចេញសំអាងហេតុតាមក្រោយ។

៤០. មានតែអង្គជំនុំជម្រះតុលាការកំពូលមួយគត់ ដែលត្រូវបានអនុញ្ញាតយ៉ាងច្បាស់ឲ្យធ្វើបែបនេះបាន ពេលត្រូវសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ[16]។ ជាអាទិ៍ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើដូច្នេះ ពេលសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃតែមួយជាមួយការបិទបញ្ចប់សវនាការលើអង្គសេចក្តី[17]។ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើរឿងដូចគ្នានេះដែរ ក្នុងឱកាសផ្សេងៗទៀត ដូចជា ពេលត្រូវសម្រេចលើការជំទាស់នឹងបញ្ជីឯកសារដែលត្រូវយកមកប្រើប្រាស់ ក្នុងពេលសាក្សីផ្តល់សក្ខីកម្ម មុនពេលចូលមកបង្ហាញ

---

[16] វិធាន ១០៨(៤) ស្ទួន នៃវិធានផ្ទៃក្នុង (វិសោធនកម្ម ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១)។

[17] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ - សេចក្តីសង្ខេបនៃសំអាងហេតុ - ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E284/4/7**, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ **E284/4/8**។

ខ្លួនចំពោះមុខតុលាការ[18]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានធ្វើដូចគ្នាផងដែរ ពេលត្រូវសម្រេចលើសំណើសុំឲ្យទទួលយកភ័ស្តុតាងបន្ថែម មុនពេលធ្វើសេចក្តីសន្និដ្ឋានការពារ[19]។

៤១. ជាបឋម អង្គបុរេជំនុំជម្រះបានចេញផ្នែកសម្រេចសេចក្តីនៃសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០២ (ដោយតម្កល់ទុកការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន រហូតដល់ពេលបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង)[20] ដែលបានធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងត្រូវទទួលសំណុំរឿងមួយនេះមកពិនិត្យ[21] មុនពេលចេញសំអាងហេតុ[22]។

---

[18] សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារ - សេចក្តីសង្ខេប - ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **F26/11**, សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារ - សំអាងហេតុពេញលេញ - ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **F26/12**។

[19] សេចក្តីសម្រេចលើសំណើសុំដាក់ភ័ស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ និងបញ្ហាពាក់ព័ន្ធ - ផ្នែកសម្រេចសេចក្តី - ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ឯកសារ **F2/9**, សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំការពិចារណាឡើងវិញនូវសេចក្តីសម្រេចកាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ស្តីពីសំណើសុំដាក់ភ័ស្តុតាងបន្ថែម ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **F2/10/3** (“សេចក្តីសម្រេច **F2/10/3**”) ទំព័រ ៥ (ដែលនៅត្រង់នោះ អង្គជំនុំជម្រះតុលាការកំពូលប្រកាសថានឹងផ្តល់សំអាងហេតុក្នុងសាលដីការបស់ខ្លួន)។

[20] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ **D427/1/26**, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ **D427/2/12**, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ **D427/4/14**។

[21] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ឯកសារ **E9** ទំព័រ ២ និងកំណត់សម្គាល់ជើងទំព័រ ១, វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង៖ អង្គជំនុំជម្រះសាលាដំបូង “ទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ”។

[22] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ **D427/4/15**, សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ **D427/2/15** និង **D427/3/15**, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ **D427/1/30**។

៤២. អង្គជំនុំជម្រះសាលាដំបូងបានធ្វើដូច្នេះជាច្រើនលើកច្រើនសា (និងច្រើនជ្រុល) ក្នុងពេលជំនុំជម្រះសំណុំរឿង ០០២/០២ ឧទាហរណ៍ ពាក់ព័ន្ធនឹងសំណើសុំទទួលយកឯកសារ សម្រាប់ការមកផ្តល់សក្ខីកម្ម[23] ឬសម្រាប់ការធ្វើសវនាការអសាធារណៈ[24] មុនពេលផ្តល់សក្ខីកម្ម។

៤៣. ក្នុងករណីទាំងនេះ សេចក្តីសម្រេច ដែលបានចេញ មានអានុភាពភ្លាមៗ និងមានផលប៉ះពាល់ផ្ទាល់លើនីតិវិធីដែលកំពុងដំណើរការ នៅពេលនោះ។ លើសពីនេះទៅទៀត សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល និងអង្គបុរេជំនុំជម្រះ ត្រូវបិទផ្លូវតវ៉ា[25]។ សេចក្តីសម្រេច ដែលអង្គជំនុំជម្រះសាលាដំបូងបានចេញ ពេលជំនុំជម្រះក្តី មិនបើកផ្លូវប្តឹងសាទុក្ខភ្លាមៗនោះទេ គឺត្រូវប្តឹងសាទុក្ខស្របពេលជាមួយបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តី[26]។ និយាយម្យ៉ាងទៀត នេះគឺជាសេចក្តីសម្រេចដែលមានផលប៉ះពាល់លើកិច្ចដំណើរការនីតិវិធី ដោយមិនចាំបាច់ឲ្យការតវ៉ាផ្នែកនីតិវិធីដែលត្រូវធ្វើឡើង ពឹងផ្អែកតាមផ្លូវច្បាប់លើការចេញសំអាងហេតុភ្លាមៗឡើយ[27]។

៤៤. ផ្ទុយទៅវិញ នៅក្នុងសំណុំរឿង ០០៤/០១ (អ៊ឹម ចែម) ពេលសហចៅក្រមស៊ើបអង្កេតចេញផ្នែកសម្រេចសេចក្តីនៃដីកាដំណោះស្រាយជាមុន និងចេញសំអាងតាមក្រោយ[28] នេះជាសេចក្តីសម្រេចបិទដំណាក់កាលនីតិវិធី (ការបញ្ចប់ដំណាក់កាលស៊ើបសួរ) ហើយបើកផ្លូវប្តឹងឧទ្ធរណ៍ភ្លាមៗ។

៤៥. ពេលនោះ អង្គបុរេជំនុំជម្រះបានប្រកាសដោយចិត្តឯងថា ការចេញសំអាងហេតុ នៅពេលក្រោយ គឺជា "វិធីសាស្ត្រដែលមិនអាចអនុវត្តចំពោះដីកាដំណោះស្រាយបានទេ" "ភាពជាក់លាក់នៃនីតិវិធី

---

[23] សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឲ្យទទួលយកឯកសារពាក់ព័ន្ធនឹងសក្ខីកម្មរបស់ 2-TCE-95 ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E367/7**, សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំឲ្យទទួលយកឯកសារចំនួន ២៩ ទាក់ទងនឹងសក្ខីកម្មរបស់អ្នកជំនាញ 2-TCE-95 ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E367/8**។

[24] ប្រតិចារឹក ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/376.1** ម៉ោង ១៣.៣៣ ដល់ ម៉ោង ១៣.៣៦, សេចក្តីសម្រេចស្តីពីសវនាការអសាធារណៈសម្រាប់សាក្សី 2-TCW-894 និង 2-TCW-938 ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E319/35/5**។

[25] វិធាន ៧៧(១៣) និងវិធាន ១០៤(៣) នៃវិធានផ្ទៃក្នុង។

[26] វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

[27] ឧទាហរណ៍ សូមមើល៖ សេចក្តីសម្រេច **F2/10/3** ទំព័រ ៥ ចំណុច "ពិចារណាឃើញថា" ចុងក្រោយ។

[28] ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **D308**, ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** (សំណៅជាភាសាបារាំងនៃឯកសារទាំងនេះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ)។

ដែលបញ្ចប់កិច្ចស៊ើបសួរជាផ្លូវការរួចហើយ" និងបានរម្លឹកថា សហចៅក្រមស៊ើបអង្កេតត្រូវចប់ភារកិច្ចពីសំណុំរឿងភ្លាម ក្រោយពេលចេញផ្នែកសម្រេចសេចក្ដីនៃដីកាដំណោះស្រាយ[29]។

៤៦. គួរឲ្យចម្លែកណាស់ អង្គបុរេជំនុំជម្រះមិនបានទាញផលវិបាក និងមិនបានសម្រេចអ្វីទាំងអស់លើអសុពលភាពនៃសំអាងហេតុ ដោយមូលហេតុសហចៅក្រមស៊ើបអង្កេតគ្មានយុត្តាធិការឡើយ។ ប្រសិនបើ អ៊ឹម ចែម មិនត្រូវបានលើកលែងការចោទប្រកាន់ ដោយសារគ្មានយុត្តាធិការបុគ្គល និងត្រូវបានបញ្ជូនទៅជំនុំជម្រះ ស្ថានភាពប្រហែលជាផ្សេងពីនេះ។

៤៧. ទោះជាក្នុងករណីណាក៏ដោយ ការចេញសំអាងហេតុលម្អិតនៃសាលក្រម ក្រោយពេលចេញផ្នែកសម្រេចសេចក្ដី ត្រូវបានហាមឃាត់ជាផ្លូវការ ហើយត្រូវទាញផលវិបាក។

## ២.២.គ. <u>ការហាមឃាត់ជាផ្លូវការនូវការបែងចែកដំណើរការធ្វើសេចក្ដីសម្រេចនៃសាលក្រម</u>

៤៨. ដូចដីកាដំណោះស្រាយដែរ សាលក្រមមានអានុភាពបញ្ចប់ដំណាក់កាលនីតិវិធី (ការបញ្ចប់ការជំនុំជម្រះក្ដីជាន់ដំបូង) និងបើកផ្លូវប្ដឹងសាទុក្ខភ្លាមៗ។ ខុសពីដីកាដំណោះស្រាយ សាលក្រមសម្រេចលើភាពមាន ឬគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទ ពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើពួកគេ និងលើការផ្ដន្ទាទោស ហើយត្រូវប្រកាស ក្នុងសវនាការជាសាធារណៈ ពេលបញ្ចប់ការជំនុំជម្រះក្ដីជាសាធារណៈ។

៤៩. នៅ អ.វ.ត.ក វិធានផ្ទៃក្នុងចែងយ៉ាងច្បាស់អំពីទម្រង់ការនៃសាលក្រម៖ ត្រូវចុះហត្ថលេខា "យ៉ាងយូរបំផុត" នៅថ្ងៃចេញសាលក្រម នៅក្នុងសវនាការជាសាធារណៈ ដែលជាពេលចាប់ផ្ដើមគិតកាលកំណត់បណ្ដឹងសាទុក្ខ សម្រាប់សហព្រះរាជអាជ្ញា និង/ឬជនជាប់ចោទដែលត្រូវបានផ្ដន្ទាទោស ក្នុងករណីជនជាប់ចោទមានវត្តមាន[30]។

៥០. ការមិនទុកចន្លោះពេលឲ្យអង្គជំនុំជម្រះសាលាដំបូង គឺដោយសារអនុភាពទាំងអស់ដែលផ្សារភ្ជាប់នឹងសាលក្រម ដោយចាប់ផ្ដើមពីការចប់ភារកិច្ចរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង តាំងពីពេលចេញសាលក្រម និងការគិតភ្លាមនូវកាលកំណត់បណ្ដឹងសាទុក្ខ។

---

[29] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ **D308/3/1/20** កថាខណ្ឌ ៣៣។

[30] សូមមើលខាងលើ កថាខណ្ឌ ៦ និងកថាខណ្ឌ ១៥-១៦។

៩១. ក្នុងករណីនេះ បើសិនជាយើងស្រមៃថា អង្គជំនុំជម្រះសាលាដំបូងមិនដឹងថា ការសរសេរសំអាងហេតុ ក្រោយការប្រកាសសាលក្រម គឺជាការរំលោភអំណាច ហេតុដូចម្ដេចបានជាអង្គជំនុំជម្រះសាលាដំបូងមិនអាចមើលឃើញបញ្ហា ដែលចោទឡើងដោយការចាកចេញរបស់ចៅក្រមអន្តរជាតិមួយរូប ក្នុងចំណោមចៅក្រមអន្តរជាតិទាំងពីររូប? ព្រោះថា បើតាមឯកសាររដ្ឋបាលរបស់តុលាការ ចៅក្រមអន្តរជាតិមួយរូបរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវត្រឡប់ទៅធ្វើការនៅតុលាការដើមរបស់ខ្លួនវិញ ដោយត្រូវចូលកាន់មុខងារថ្មី នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨[31]។

៩២. លើកលែងតែករណីនេះមានន័យផ្ទុយទៅវិញថា អង្គជំនុំជម្រះសាលាដំបូងដឹងច្បាស់ថាខ្លួននឹងចប់ភារកិច្ចពីសំណុំរឿង តាំងពីពេលប្រកាសសាលក្រម ដោយសង្ឃឹមថា គ្មាននរណាម្នាក់លើកឡើងអំពីភាពគ្មានយុត្តាធិការ និងអសុពលភាពនៃសំអាងហេតុជាលាយលក្ខណ៍អក្សរ ពេលប្ដឹងសាទុក្ខនោះទេ។

៩៣. ទោះជាយ៉ាងណាក៏ដោយ មេធាវីការពារក្ដីមិនអាចរង់ចាំដល់ពេលចេញសំអាងហេតុពេញលេញដើម្បីលើកឡើងអំពីបញ្ហានេះបានឡើយ។ វិធានផ្ទៃក្នុងមិនចែងអំពីឧបាស្រ័យប្រឆាំងនឹងឯកសារបែបនេះឡើយ ខណៈដែលកាលកំណត់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមបានចាប់ផ្ដើមគិតចាប់ពីថ្ងៃប្រកាសសាលក្រម។

៩៤. អាស្រ័យហេតុនេះ ក្នុងស្ថានភាពច្របូកច្របល់ខ្លាំងនេះ ច្បាស់ណាស់ថាលោក ខៀវ សំផន ត្រូវតែលាតត្រដាងកំហុសអង្គច្បាប់ដែលនាំឲ្យសាលក្រមរបស់អង្គជំនុំជម្រះក្លាយជាមោឃៈ តាំងពីឥឡូវនេះទៅ។

## ៣. *កំហុសអង្គច្បាប់ដែលនាំឲ្យសាលក្រមក្លាយជាមោឃៈ*

៩៥. ដូចបានឃើញពីខាងលើ[32] យោងតាមច្បាប់ជាធរមាន នៅ អ.វ.ត.ក សាលក្រមដែលប្រកាសត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ដូចអង្គជំនុំជម្រះតុលាការកំពូលធ្លាប់បានរម្លឹករួចមកហើយ កាតព្វកិច្ចនេះត្រូវតែគោរពតាម បើមិនអ៊ីចឹងទេ សាលក្រមត្រូវទុកជាមោឃៈ។

---

[31] ផែនការបញ្ចប់ការងារ កំណែប្រែលើកទី ១៨ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ ៣៤ (ដាក់បង្ហាញលើវេបសាយត៍របស់ អ.វ.ត.ក នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៨)។

[32] សូមមើលផ្នែកទី “១. ការរំលោភលើវិធានផ្ទៃក្នុង” កថាខណ្ឌ ៥-៧។

៩៦. ពេលពិចារណាលើលក្ខណៈគតិយុត្តិ និងអានុភាពនៃសេចក្តីសម្រេចផ្ទាល់មាត់ ដែលលោក នួន ជា បានប្តឹងសាទុក្ខភ្លាមៗ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា៖ "តាមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក សេចក្តីសម្រេច ដែលខ្វះទម្រង់ជាលាយលក្ខណ៍អក្សរ លើកលែងតែសាលក្រម ពុំបានបណ្តាលឲ្យមានមោឃភាពឡើយ"[33]។ និយាយម្យ៉ាងទៀត ការមិនចេញសាលក្រមជាលាយលក្ខណ៍អក្សរ គឺជាមូលហេតុនៃមោឃភាព។

៩៧. នៅពេលនោះ អង្គជំនុំជម្រះតុលាការកំពូលបានរម្លឹកថា "ជាទម្លាប់អនុវត្តន៍ដ៏ខ្ជាប់ខ្ជួនរបស់ អ.វ.ត.ក ដែលសេចក្តីសម្រេច ដែលបើកផ្លូវប្តឹងសាទុក្ខ ត្រូវចេញជាលាយលក្ខណ៍អក្សរ" ជាពិសេស យោងលើភាពស្មុគស្មាញនៃបញ្ហាដែល អ.វ.ត.ក បានដោះស្រាយ៖

"ការអនុវត្តន៍នេះ ទោះបីជាមិនបានតម្រូវដោយច្បាប់ក៏ដោយ ក៏បានផ្តល់នូវភាពច្បាស់លាស់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី ដូចមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ហើយនិងអាចផ្តល់ឲ្យមានដំណើរការពិនិត្យមើលឡើងវិញ ប្រកបដោយប្រសិទ្ធភាព។ ជាងនេះទៀត ដូចអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងក្នុងឱកាសខុសៗគ្នាថា រាល់សេចក្តីសម្រេចតាមផ្លូវតុលាការទាំងអស់ មិនថាជាសេចក្តីសម្រេចផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរឡើយ ត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់សំអាងហេតុគ្រប់គ្រាន់ ចំពោះសេចក្តីសម្រេចទាំងនោះ ដែលជាផលនៃការគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជាការពិតណាស់ សិទ្ធិទទួលបានសេចក្តីសម្រេច ដែលមានសំអាងហេតុពេញលេញ គឺជាផ្នែកមួយនៃសិទ្ធិទទួលបានការជំនុំជម្រះ"[34]។

៩៨. វិធានផ្ទៃក្នុងបញ្ញត្តជាក់លាក់ និងច្បាស់លាស់អំពីកាតព្វកិច្ចនេះចំពោះសាលក្រម ដោយគោរពតាមមាត្រា ១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[35] ដែលចែងថា "ជន

[33] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E176/2/1/4** កំណត់សម្គាល់ជើងទំព័រ ៧៨ (កថាខណ្ឌ ២៥)។

[34] ដូចខាងលើ កថាខណ្ឌ ២៥ និងកំណត់សម្គាល់ជើងទំព័រ ៧៨។

[35] កិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពី អ.វ.ត.ក មាត្រា ១៣(១)៖ "សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិ ឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី"។

គ្រប់រូប ដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញ ស្របតាមច្បាប់"។

៥៩. នេះជាសិទ្ធិ "សុំឱ្យពិនិត្យលើអង្គសេចក្តីលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោស ដោយផ្ទៀងផ្ទាត់មើលថា តើមានភ័ស្តុតាងគ្រប់គ្រាន់ និងស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ដែរឬទេ"[36]។ ការពិនិត្យមើលឡើងវិញ ដែល "ពាក់ព័ន្ធតែទិដ្ឋភាពផ្លូវការ ឬទិដ្ឋភាពច្បាប់នៃសាលក្រមមិនស្របតាមការធានា ដែលតម្រូវដោយកថាខណ្ឌ ៥ នៃមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ"[37]។ ដើម្បីអនុវត្តសិទ្ធិនេះឱ្យមានប្រសិទ្ធភាព សាមីជនត្រូវអាចទទួលបានអត្ថបទជាលាយលក្ខណ៍អក្សរនៃសាលក្រមដែលមានសំអាងហេតុត្រឹមត្រូវ ពីយុត្តាធិការជំនុំជម្រះ"[38]។

៦០. ជាក់ស្តែង នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែប្រកាសផ្នែកសម្រេចសេចក្តីនៃសាលក្រម និងអានសេចក្តីសង្ខេបនៃសំអាងហេតុ ដោយមិនបានផ្តល់សំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរឡើយ។ ក្នុងលក្ខខណ្ឌទាំងនេះ ច្បាស់ណាស់ថាលោក ខៀវ សំផន មិនអាចប្តឹងសាទុក្ខលើអង្គសេចក្តីប្រឆាំងនឹងការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសបានទេ។

៦១. សេចក្តីសង្ខេបមិនត្រឹមតែមិនអនុញ្ញាតឱ្យពិចារណាលើភាពគ្រប់គ្រាន់នៃភ័ស្តុតាងពិនិត្យ និងច្បាប់ដែលយកមកអនុវត្តបានទេ ថែមទាំងមិនអាចឱ្យរកឃើញកំហុសអង្គច្បាប់ និងអង្គច្បាប់ បានទៀតផង។ ដូច្នេះ សេចក្តីសង្ខេបនេះមិនអាចយកជាការបានទេ[39]។

---

[36] *Bandajevsky ទល់នឹងប្រទេសបេឡារុស* ឯកសារផ្សព្វផ្សាយលេខ ១១០០/២០០២ សេចក្តីសង្កេតរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ១០(១៣)។

[37] *Gómez Vázquez ទល់នឹងប្រទេសអេស្ប៉ាញ* ឯកសារផ្សព្វផ្សាយលេខ ៧០១/១៩៩៦ សេចក្តីសង្កេតរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០០ កថាខណ្ឌ ១១(១)។

[38] *Van Hulst ទល់នឹងប្រទេសហូល្លង់* ឯកសារផ្សព្វផ្សាយលេខ ៩០៣/១៩៩៩ សេចក្តីសង្កេតរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ ៦(៤)។

[39] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ សេចក្តីព្រាង បន្ទាប់ពីម៉ោង [០៩:៣៣:៣៦] "អង្គជំនុំជម្រះប្រកាសនូវសេចក្តីសង្ខេបនៃសាលក្រម [០០២/០២] តែប៉ុណ្ណោះ ដោយសំអាងហេតុដែលមានអានុភាពតាមផ្លូវច្បាប់ គឺជាសំអាងហេតុដែលសរសេរពេញលេញជាលាយលក្ខណ៍អក្សរនៅក្នុងសាលក្រម ដែលមានជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ដែលអង្គជំនុំជម្រះនឹងចេញនៅក្នុងពេលសមស្របខាងមុខ។" ពេលប្រកាសសាលក្រម សំណុំរឿង ០០២/០១ លោកប្រធានបានប្រកាសថា៖ "ខាង

៦២. ក្រៅពីនេះទៀត ខណៈដែលកាលកំណត់ធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមបានចាប់ផ្ដើមគិតអត្ថបទនៃសំអាងហេតុពេញលេញ ដែលត្រូវសន្មតថាមានអនុភាពតាមផ្លូវច្បាប់តែមួយគត់ ដែលត្រូវប្រកាស "ក្នុងពេលសមស្រប" នឹងគ្មានមូលដ្ឋានច្បាប់ ឬតម្លៃគតិយុត្តិឡើយ ដោយសារតែភាពគ្មានយុត្តាធិការរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវចប់ភារកិច្ចពីសំណុំរឿងរួចទៅហើយ។ មិនមានការថែងអំពីឧបាស្រ័យ ក្នុងករណីបែបនេះទេ។

៦៣. ដូច្នេះ លោក ខៀវ សំផន មិនអាចប្ដឹងសាទុក្ខលើអង្គសេចក្ដីប្រឆាំងនឹងការប្រកាសពិរុទ្ធភាព និងការផ្ដន្ទាទោស នាពេលឥឡូវនេះ ឬនាពេលក្រោយ បានឡើយ។ តាមន័យទូលាយ ការមិនអាចប្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក៏ធ្វើឲ្យមិនអាចប្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេច ដែលបានធ្វើឡើងក្នុងពេលជំនុំជម្រះក្ដី ដែលបើកផ្លូវប្ដឹងសាទុក្ខបានស្របពេលជាមួយបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម[40]។

៦៤. ដូច្នេះ កំហុសអង្គច្បាប់ ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្ត ធ្វើឲ្យសាលក្រមក្លាយជាមោឃៈ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងបានដកហូតដោយមិនត្រឹមត្រូវនូវលទ្ធភាពរបស់មេធាវីការពារក្ដី ក្នុងការធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម និងសេចក្ដីសម្រេចនានាដែលបើកផ្លូវប្ដឹងសាទុក្ខ ស្របពេលជាមួយបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្ដី។

## ៤. ការរំលោភលើសិទ្ធិរបស់លោក ខៀវ សំផន និងព្យសនកម្ម

៦៥. ទន្ទឹមនឹងការរំលោភលើបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបានរំលោភលើសិទ្ធិខាងនីតិវិធីរបស់លោក ខៀវ សំផន សិទ្ធិទទួលបានតម្លាភាពនៃកិច្ចដំណើរការនីតិវិធី សិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ សិទ្ធិធ្វើបណ្ដឹងសាទុក្ខ និងសិទ្ធិទទួលបានការកាត់សេចក្ដីលើរឿងក្ដីរបស់ខ្លួន ដែលបង្កព្យសនកម្មធ្ងន់ធ្ងរដល់រូបគាត់។

---

ក្រោមនេះ គឺជាសេចក្ដីសង្ខេបសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១។ សំអាងហេតុ ដែលមានអានុភាពតាមផ្លូវច្បាប់ គឺជាសំអាងហេតុដែលសរសេរពេញលេញជាលាយលក្ខណ៍អក្សរ ក្នុងសាលក្រម ដែលអាចរកបានភ្លាមៗ ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ក្រោយពីសវនាការប្រកាសសាលក្រមនេះ"៖ ប្រតិចារឹក ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ **E1/241.1** ទំព័រ ២ ក្រោយម៉ោង ០៩.០៧។

[40] វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

៦៦. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ លោក ខៀវ សំផន ត្រូវបានប្រកាសថាមានពិរុទ្ធពីបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុតនៅលើពិភពលោក និងត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត នៅចំពោះមុខសាធារណជន ដែលមានសមាសភាព ជាអាទិ៍ មន្ត្រី និងអ្នកការទូត (រួមទាំងអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ និងទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ) ក្នុងតុលាការអន្តរជាតិក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ដែលគ្រប់ផ្លូវទាំងអស់ទៅកាន់សាលសវនាការទើបតែត្រូវបានលាបថ្នាំថ្មី សម្រាប់ឱកាសនៃការប្រកាសសាលក្រមជាប្រវត្តិសាស្ត្រនេះ។

៦៧. ដោយសារការផ្តន្ទាទោសត្រូវបានប្រព័ន្ធព័ត៌មានជាតិ និងអន្តរជាតិ ផ្សព្វផ្សាយបន្តយ៉ាងទូលំទូលាយ លោក ខៀវ សំផន ត្រូវទទួលរងនូវក្តីអាម៉ាស់នៅកម្រិតពិភពលោក ដោយសារតែការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ខណៈដែលគាត់ស្ថិតក្នុងស្ថានភាពមិនអាចប្តឹងសាទុក្ខលើអង្គសេចក្តីបាន។

៦៨. បណ្តឹងសាទុក្ខ ពាក់ព័ន្ធតែនឹងទិដ្ឋភាពផ្លូវការនៃសាលក្រមនេះ មិនអាចកាត់បន្ថយព្យសនកម្មដែលទទួលរងបានទេ ពីព្រោះសាលក្រមមិនស្របតាមការធានាដែលតម្រូវដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងវិធានផ្ទៃក្នុង។

<u>សេចក្តីសន្និដ្ឋាន</u>

៦៩. យោងលើព្យសនកម្ម សារៈសំខាន់ និងផលប៉ះពាល់នៃបញ្ហាដែលបានលើកឡើង អង្គជំនុំជម្រះតុលាការកំពូលត្រូវអន្តរាគមន៍ឲ្យបានឆាប់បំផុត ប្រសិនបើអាច គឺមុនពេលជូនដំណឹងអំពីសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរ។

៧០. ប្រសិនបើជាវិសាមញ្ញ អង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្តល់សុពលភាពដល់ការរំលោភលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះសាលាដំបូង និងមិនធ្វើមោឃភាពសាលក្រម ដែលបានប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយមូលហេតុវិការៈទម្រង់ និងគ្មានសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល គប្បីលើកពេលចាប់ផ្តើមកាលកំណត់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តី។ ជាការពិត អង្គជំនុំជម្រះតុលាការកំពូលគប្បីយល់ឃើញថា បណ្តឹងសាទុក្ខប្រឆាំងនឹងទម្រង់ការនៃសាលក្រមនេះត្រូវបានធ្វើឡើងជាលក្ខណៈរក្សាការពារ ក្នុងន័យរក្សាការពារលទ្ធភាពធ្វើបណ្តឹងសាទុក្ខលើអង្គសេចក្តីប្រឆាំងនឹងសាលក្រម ពេលមានសំអាងហេតុត្រឹមត្រូវ។

៧១. ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្ដីសម្រេចបែបនេះ មុនពេលជូនដំណឹងអំពីសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរ (ឬបន្ទាប់ពីការជូនដំណឹងពីសំអាងហេតុពេញលេញជាពីរភាសា) អង្គជំនុំជម្រះតុលាការកំពូលគប្បីលើកកាលកំណត់បណ្ដឹងសាទុក្ខ ចាប់ពីពេលជូនដំណឹងអំពីសំអាងហេតុនេះដែលធ្វើឡើងជាបីភាសាផ្លូវការរបស់ អ.វ.ត.ក ដើម្បីអោយភាគីនីមួយៗអាចអនុវត្តសិទ្ធិប្ដឹងសាទុក្ខយ៉ាងមានប្រសិទ្ធិភាព។ ហើយអង្គជំនុំជម្រះតុលាការកំពូលក៏បានដឹងច្បាស់ហើយអំពីភាពចាំបាច់របស់ភាគីនីមួយៗ ក្នុងការទទួលបានសាលក្រមជាពីរភាសា ដែលជាភាសាការងាររបស់ខ្លួនសម្រាប់ធ្វើបណ្ដឹងសាទុក្ខ ដែលនេះជាដើមហេតុនៃការយល់ច្រឡំលើមាត្រា ៨.៥ នៃសេចក្ដីណែនាំអនុវត្ត។[41]

៧២. ផ្ទុយទៅវិញ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្ដីសម្រេចនេះ ក្រោយការជូនដំណឹងអំពីសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះសាលាដំបូង ទាំងបីភាសាផ្លូវការ អង្គជំនុំជម្រះតុលាការកំពូលគប្បីលើកកាលកំណត់បណ្ដឹងសាទុក្ខ ចាប់ពីពេលជូនដំណឹងអំពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខនេះ។

៧៣. **<u>អាស្រ័យហេតុនេះ</u>** មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

- **សម្រេច**ជាបន្ទាន់
- **ប្រកាស**ទទួលយកបណ្ដឹងសាទុក្ខនេះ
- **ធ្វើមោឃភាព**សាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨
- **ទទួលស្គាល់**អសុពលភាពនៃសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរ ដែលនឹងចេញនាពេលខាងមុខ

*បើមិនដូច្នេះទេ*

- **លើកពេល**ចាប់ផ្ដើមកាលកំណត់បណ្ដឹងសាទុក្ខ ចាប់ពីពេលជូនដំណឹងអំពីសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះសាលាដំបូងទាំងបីភាសាផ្លូវការរបស់អ.វ.ត.ក

[41] សូមមើលខាងលើ កថាខណ្ឌ ១៣-១៤ និងកថាខណ្ឌ ១៨-១៩។

ឬចាប់ពីពេលជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ប្រសិនបើសេចក្តីសម្រេចនេះចេញក្រោយពេលជូនដំណឹងអំពីសំអាងហេតុនេះ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ | |